**សុន្ទរកថារបស់លោក យូណាមីណិ ម៉ូរីយ៉ាស៊ុ**
**លេខាទី ២ នៃស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីសម្ពោធមណ្ឌលសុខភាព មិត្តភាពកម្ពុជា ជប៉ុន ចំបក់**
**ខេត្តកំពង់ស្ពឺ**
**ថ្ងៃទី ០៥ ធ្នូ ឆ្នាំ ២០១៤**

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ!
- សូមគោរព **ឯឧត្តម សាស្ត្រាចារ្យ វេជ្ជបណ្ឌិត អេង ហួត** រដ្ឋលេខាធិការក្រសួងសុខាភិបាល ជាទីគោរព
- សូមគោរព **ឯកឧត្តម អ៊ូ សំអួន** អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ
- សូមគោរព **កញ្ញា អេស្វេល រ៉ូស** អ្នកតំណាងប្រចាំប្រទេសរបស់អង្គការកុមារ និងអភិវឌ្ឍន៍
- សូមគោរព **លោក វេជ្ជបណ្ឌិត, អោ វណ្ណថេន** ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺ
- សូមគោរព អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់

ខ្ញុំមានសេក្តីសោមនស្សរីករាយក្រៃលែង ដែលបានចូលរួមក្នុងពិធីសម្ពោធសម្រោងសម្រាប់សាងសងមណ្ឌលសុខភាពមិត្តភាព កម្ពុជា ជប៉ុន ចំបក់ ក្នុងខេត្តកំពង់ស្ពឺ ដែលមានវត្តមានដ៏ខ្ពង់ខ្ពស់របស់ឯឧត្តម សាស្ត្រាចារ្យ វេជ្ជបណ្ឌិត អេង ហួត រដ្ឋលេខាធិការក្រសួងសុខាភិបាល។ ជាបឋមខ្ញុំសូមសំដែងនូវការ ដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមរដ្ឋលេខាធិការ ឯកឧត្តម អភិបាលខេត្ត និងបុគ្គលិកអង្គការកុមារ និងអភិវឌ្ឍន៍ ព្រមទាំងភ្ញៀវកិត្តិយសទាំងអស់ដែលបានចូលរួមក្នុងកម្មពិធីនេះ។

ការពង្រីកផ្នែកសុខាភិបាល គឺជាការកំណែទម្រង់មួយដ៏សំខាន់នៃបណ្តាកំណែទម្រង់ដទៃទៀត ដែលបានធ្វើអោយមានការរីកចម្រើនជាលំដាប់ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីបី របស់រាជរដ្ឋាភិបាលកម្ពុជា។ រដ្ឋាភិបាលជប៉ុនបាននឹងកំពុងគាំទ្រដល់កិច្ចខំប្រឹងប្រែងរបស់កម្ពុជាក្នុងការពង្រឹងផ្នែកសុខាភិបាល តាមរយៈការអភិវឌ្ឍន៍ធនធានមនុស្ស និងការ កែលម្អស្ថានភាព មណ្ឌលសុខភាព ការថែទាំវេជ្ជសាស្ត្រ រួមមាន កសាងសង់មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក តាមរយៈការជំនួយឥតសំណង។

គម្រោងនេះ គឺដើម្បីសាងសង់មណ្ឌលសុខភាព ព្រមទាំបំពាក់ទៅដោយ ឡដុតកាកសំណល់វេជ្ជសាស្ត្រមួយ របងមួយ និងធុងទឹកមួយ ក្នុងឃុំចំបក់ ស្រុកភ្នំស្រួច ខេត្ត កំពង់ស្ពឺ។ គម្រោងនេះមាន គោលបំណងអោយអ្នកជម្ងឺទទួលបានការព្យាបាល អោយកាន់តែមានសុវត្ថិភាព និងមានការយកចិត្តទុកដាក់ខ្ពស់ ហើយគម្រោងនេះត្រូវបានរំពឹងថានឹងចូលរួមចំណែក ជួយសម្រាលស្ថានភាពសុខភាពនៅក្នុងតំបន់នេះ។

ជាចុងក្រោយខ្ញុំសង្ឃឹមយ៉ាងមុតមាំថា មណ្ឌលសុខភាពមិត្តភាព កម្ពុជា ជប៉ុន ចំបក់នេះ នឹងពង្រីក ការផ្តល់សេវាសុខាភិបាលនៅក្នុងខេត្តកំពង់ស្ពឺ ហើយជាលទ្ធផលប្រជាពលរដ្ឋជាច្រើននឹងទទួល បានអត្ថប្រយោជន៍ ពិសេវាសុខាភិបាលកាន់តែប្រសើឡើងដែលផ្តល់ដោយមន្ទីរពេទ្យ។ ខ្ញុំសង្ឃឹមដោយស្មោះថា មណ្ឌលសុខភាពនេះ នឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវ នឹងប្រើប្រាស់ប្រកបដោយ ប្រសិទ្ធិភាពជាយូរអង្វែង ដើម្បីទុកជានិមិត្តរូបនៃទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់។**